# មជ្ឈមណ្ឌលឯកសារកម្ពុជា

**PTI0070**

### សម្ភាសជាមួយឈ្មោះ សួន ខុត ភេទប្រុស អាយុ ៥៥ឆ្នាំ
### មុខងារខ្មែរក្រហមៈ និរសាកងទ័ព
### មុខងារបច្ចុប្បន្នៈ ធ្វើស្រែ
### មានស្រុកកំណើតនៅៈ ភូមិអញ្ចាញ ឃុំជើងក្នួន ស្រុកសំរោង ខេត្តតាកែវ
### សព្វថ្ងៃរស់នៅភូមិប្រមោយ ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់
### ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១១
### សម្ភាសន៍ដោយៈ សោម ប៊ុនថន

០១:០២:៣៥

២៦ ទំព័រ

ប៊ុនថន : អញ្ចឹងជីបូងខ្ញុំសុំអនុញ្ញាតសម្ភាសន៍អ៊ំៗអនុញ្ញាតឲ្យខ្ញុំសម្ភាសន៍ទេអ៊ំ?

ខុត : បាទ!សម្ភាសន៍ទៅមានអី ។

ប៊ុនថន : បាទៗ!អ៊ំជីបូងចង់សួរឈ្មោះអ៊ំៗឈ្មោះអីដែរ?

ខុត : ឈ្មោះ សួន ខុត ។

ប៊ុនថន : សួន ខុត អាយុប៉ុន្មានហើយអ៊ំ?

ខុត : អាយុ៥៥ ។

ប៊ុនថន : ៥៥ឆ្នាំ?

ខុត : បាទ!

ប៊ុនថន : អ៊ំមានស្រុកកំណើតនៅភូមិឃុំអីដែរអ៊ំ?

ខុត : ខ្ញុំនៅភូមិអញ្ចាញ ឃុំជើងក្នួន ស្រុកសំរោង ខេត្តតាកែវ ។

ប៊ុនថន : បាទ!សព្វថ្ងៃអ៊ំរស់នៅភូមិឃុំអីដែរអ៊ំ?

ខុត : សព្វថ្ងៃខ្ញុំរស់នៅភូមិប្រមោយ ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។

ប៊ុនថន : អ៊ំមានបងប្អូនប៉ុន្មាននាក់អ៊ំ?

ខុត : បងប្អូននៅសល់តែ២នាក់ទេ ក្រោពីហ្នឹងគេវៃចោលអស់ អាហ្នឹង៤នាក់ គេវៃចោលអស់ហើយមិនដឹងណាៗអត់ដឹងផង ។

ប៊ុនថន : ស្រីប៉ុន្មាន ប្រុសប៉ុន្មានកាលហ្នឹង?

ខុត : ស្រី២ ឯាប់ទាំង២ ។

ប៊ុនថន ៖ អ្ហូ! នៅតែប្រុសៗទេ?

ខុត ៖ នៅតែប្រុសៗ ។

ប៊ុនថន ៖ អ៊ំកូនទីប៉ុន្មាន?

ខុត ៖ ខ្ញុំបន្ទាប់បងទី១ ។

ប៊ុនថន ៖ ហើយគាត់ឆ្នាំប៉ុន្មាន ប្អូនៗហ្នឹង?

ខុត ៖ បងខ្ញុំស្លាប់គេចោទថាក្បត់នេះ អាបងខ្ញុំបង្កើតហ្នឹង ។

ប៊ុនថន ៖ អ្ហូ! បងប្រុសហ្នឹង?

ខុត ៖ គេចោទ ខ្មែរក្រហមយកទៅបាញ់ចោល ។

ប៊ុនថន ៖ នៅណាវិញអ៊ំ?

ខុត ៖ នៅភ្នំ ឆត្រ ។

ប៊ុនថន ៖ នៅភ្នំឆត្រ ស្លាប់ឆ្នាំប៉ុន្មានគាត់?

ខុត ៖ ស្លាប់នៅខ្ទង់ប្រហែល៨៥ ។

ប៊ុនថន ៖ អ្ហូ! ពេលវៀតណាមចូលម៉ោហើយហ្នឹងម៉េច?

ខុត ៖ ហ្នឹងហើយ ៨៥ស្លាប់ អ្ហូ! អត់៨៥ទេ ឆ្នាំ៨២ស្លាប់ ។

ប៊ុនថន ៖ បាទ! ៨២ កាលហ្នឹងគាត់ធ្វើអីដែរអ៊ំ?

ខុត ៖ គាត់កងអានុសេនាធំ ។

ប៊ុនថន ៖ បាទ! ម៉េចបានអ៊ំដឹងថាគាត់ស្លាប់អ៊ំ?

ខុត ៖ ក្មេងៗកងនិរសាគាត់រត់ម៉ោប្រាប់ខ្ញុំ តាមផ្លូវជួរអន្លង់វែងហ្នឹង ។

ប៊ុនថន ៖ កាលគាត់គេយក?

ខុត ៖ គេយកទៅបាញ់ចោលយប់ ។

ប៊ុនថន ៖ គាត់ឈ្មោះអីវិញអ៊ំ?

ខុត ៖ ឈ្មោះ សួន នៀល ។

ប៊ុនថន ៖ សួន នៀល?

ខុត ៖ បាទ! ។

ប៊ុនថន ៖ បាទ! ហើយអ៊ំមានដឹងថាម៉េចបានគេសម្លាប់គាត់ទេ?

ខុត ៖ គេថាយើងនាំកម្លាំងទាក់ទងជាមួយខាងក្នុង ហើយយើងនាំកម្លាំងចូលសារភាព ចូលសារភាពខាងយើងខាងខ្មែរយើង ។

ប៊ុនថន : ចុះខាងណាអ្នកសម្លាប់?

ខុត : អត់ស្គាល់ឈ្មោះផងយប់ គេបាញ់យប់ ។

ប៊ុនថន : ប៉ុនអត់បានដឹងណាទេ?

ខុត : មិនដឹងខាងណាអ្នកសម្លាប់ យប់គេថាគេឲ្យសំបុត្រម៉ោមួយ មើលហើយទៅគេបាញ់ដើមទ្រូងគាត់៣គ្រាប់ស្លាប់ ។

ប៊ុនថន : ចុះអ៊ំមានបានទៅចូលរួមអីទេ ពេល?

ខុត : អត់ហានទៅចូលរួមផង ឆ្ងាយពីគ្នា ឆ្ងាយខ្លាំងណាស់ ដើរទៅមាំថ្ងៃនោះ ។

ប៊ុនថន : បាទ!កាលហ្នឹងគាត់អនុសេនាធំលេខប៉ុន្មានអ៊ំមានដឹងទេ?

ខុត : អត់ដឹងរលីង ។

ប៊ុនថន : ចុះគាត់នៅជាមួយពីណាអ៊ំ?

ខុត : កាលហ្នឹង?

ប៊ុនថន : បាទ!

ខុត : កាលហ្នឹងនៅជាមួយកងពីណាគេឈ្មោះគេ គីម ហេង១ប៉ុនគេបាញ់ចោលបាត់ ហើយ ។

ប៊ុនថន : គីម ហេង?

ខុត : បាទ!ងាប់បាត់ អញ្ចឹងបានខ្ញុំថាអ៊ើ!អ្នកណាធ្វើបុណ្យចង្រៃវាវាញទៅជាគ្រោះ សម្លាប់ គេគេឃើញផ្ទាល់នឹងភ្នែកច្រើនណាស់ឲ្យតែសម្លាប់គេអញ្ចឹងហ្នង ។

ប៊ុនថន : បាទ!អញ្ចឹងប្អូនស្រីអ៊ំ២នាក់ហ្នឹងស្លាប់?

ខុត : ស្លាប់នៅផ្ទះ ។

ប៊ុនថន : គាត់ស្លាប់នៅសម័យតស៊ូ៣ឆ្នាំ?

ខុត : ស្លាប់នៅសម័យតស៊ូ៣ឆ្នាំ១នាក់ ១ទៀតឈឺរ៉ាំរ៉ៃ សុទ្ធតែឈឺរ៉ាំរ៉ៃដូចតែគ្នាហ្នឹងតែគេអត់អី ។

ប៊ុនថន : ចុះអ៊ំរៀនសូត្រដល់ថ្នាក់ណាដែរអ៊ំ?

ខុត : ខ្ញុំរៀនសូត្រដល់ថ្នាក់ទី៩ ។

ប៊ុនថន : ថ្នាក់ទីសង្គមចាស់អ៊ំ?

ខុត : ទី៩ចាស់ ។

ប៊ុនថន : នៅសាលាណាអ៊ំកាលហ្នឹង?

ខុត : នៅវត្តក្តីទន្ទឹម ។

ប៊ុនថន ៖ វត្តក្តីទន្ទឹម?

ខុត ៖ បាទ! នៅក្នុងស្រុកភូមិខ្ញុំហ្នឹងហ្នង ។

ប៊ុនថន ៖ បាទ! ចុះឪពុកម្តាយអ៊ំនៅរស់ទេសព្វថ្ងៃ?

ខុត ៖ ឪពុកម្តាយស្លាប់នៅសម័យកសាង នៅសល់តែឪ បាទ! ឪហ្នឹង១ថ្ងៃគាត់១ថ្ងៃកោរ គាត់អាយុ៨២ហើយយ៉ាង ។

ប៊ុនថន ៖ អ្ហូ! បានអាយុ៨២ហើយ?

ខុត ៖ បាទ! គាត់ឲ្យខ្ញុំទៅ ខ្ញុំទៅអត់រួចផង គាត់ក៏ម៉ោអត់រួច ផ្ទះជិតគ្នាប្រហែលជា៥គីឡូពី គ្នា ។

ប៊ុនថន ៖ គាត់នៅនេះដែរអ៊ំ?

ខុត ៖ នៅតាកែវ ។

ប៊ុនថន ៖ បាទ! ព្វថាអ៊ំទឹមម៉ោពីតាកែវដែរអ៊ំ?

ខុត ៖ ខ្ញុំទឹមម៉ោបាន១ថ្ងៃ ទឹមម៉ោគេតាស់ៗម៉ោទៀតម៉ោ ។

ប៊ុនថន ៖ បាទ! ហើយអ៊ំបន្ទាប់ពីឈប់រៀនហើយអ៊ំធ្វើអីក្រោយម៉ោ?

ខុត ៖ ខ្ញុំបន្ទាប់ពីឈប់រៀនហើយខ្ញុំនៅមន្ទីរចិញ្ចឹមជ្រូក ចេះចិញ្ចឹមជ្រូកអញ្ចឹងទៅ គេឲ្យចិញ្ចឹម ជ្រូក ចិញ្ចឹមជ្រូកហ្នឹងជ្រូក១២ក្បាលនោះ កាប់ដើមចេកឲ្យស៊ីរាល់ថ្ងៃ ។

ប៊ុនថន ៖ បាទ!

ខុត ៖ គេធ្វើការគេយកទៅធ្វើការយកទៅ យើងចិញ្ចឹមជ្រូក គេថាលត់ដំទាល់តែចិញ្ចឹមជ្រូក សិនប៉ុនធ្វើទាហានទ័ពកើត បាន២ឆ្នាំ ។

ប៊ុនថន ៖ បាទ! កាលហ្នឹងគេហៅមន្ទីរអីវិញអ៊ំ?

ខុត ៖ មិនដឹងមន្ទីរអី ប្រធានកសិដ្ឋានហ្នឹង ។

ប៊ុនថន ៖ បាទ! ដូចហៅមន្ទីរកុមារ មន្ទីរ?

ខុត ៖ អាហ្នឹងហៅមន្ទីរកុមារ ។

ប៊ុនថន ៖ មន្ទីរកុមារនៅស្រុកភូមិអ៊ំហ្នឹង?

ខុត ៖ នៅស្រុកភូមិហ្នឹង នៅកណ្តាលព្រៃ នៅឆ្ងាយពីផ្ទះប្រហែលជាប់២គីឡូ ៣គីឡូដែរព្រៃ ខ្មោច ។

ប៊ុនថន ៖ គេហៅអីវិញកាលហ្នឹងអ៊ំ ភូមិអីវិញ?

ខុត ៖ អាហ្នឹងគេហៅភូមិស្អីគេ នៅអញ្ចឹងពិបាកហៅទៀតអាភូមិមានព្រៃហ្នឹង ខ្ញុំឆ្ងាយពីផ្ទះវា ជាប់នៅខ្សែភូមិស្វាយមិនដឹងត្រង់ណាទេ ។

ប៊ុនថន : អញ្ចឹងពេលអ៊ំចេញពីមន្ទីរហ្នឹងគេឲ្យធ្វើអីដែរ?

ខុត : ចេញពីមន្ទីរម៉ោ គេរើសម៉ោធ្វើនិរសាទៅ ។

ប៊ុនថន : និរសា?

ខុត : និរសាវ៉ៃគេ ម៉ោតាមផ្លូវលេខ៤ ចេះតែម៉ោគេឯងទៅ ខ្ញុំតូចគេឲ្យដាំបាយ ។

ប៊ុនថន : អ៊ំខាងដាំបាយ?

ខុត : ដាំបាយគេឲ្យខ្ញុំបាយខ្ញុំចេះដាំទៅ រ៉ែកឲ្យគេអញ្ចឹងទៅ បាយស្ទុកចេះតែរ៉ែកទៅ ។

ប៊ុនថន : អ៊ំនៅនិរសាកងទ័ពកាលហ្នឹង?

ខុត : នៅនិរសាអនុសេនាធំគេកងទ័ព ។

ប៊ុនថន : បាទ!អនុសេនាធំលេខប៉ុន្មានអ៊ំកាលហ្នឹង?

ខុត : កាលហ្នឹងអនុសេនាធំលេខ១ កងគេកងផ្លាស់ប្តូរហូតវរៈសេនាតូចគេ ហើយយើងកំណត់ថា១០១ទៅ ឥឡូវវាឡើងដល់១០២-១០៣ឯណាមុនៗអាខ្លះគេឡើងទៅភាគទៅអីអស់ ខ្ញុំសុំគេឡើង គេមិនឲ្យឡើង ។

ប៊ុនថន : ម៉េចបានគេមិនឲ្យអ៊ំឡើង?

ខុត : អត់!គេថាហេងដាំបាយចុះ មេហ្នឹងគាត់មិនឡើងដែរ ។

ប៊ុនថន : មេហ្នឹងអត់ឡើងដែរ?

ខុត : អត់ សមតែបានឡើងសុំវាបានឡើងអាហ្នឹងចូល៧៥នេះ ៧៥បានចូលដល់កំពង់ស្ពឺ បានចូលមួយថ្ងៃហ្នឹង ប៉ុនសសើរតែជីវិតនៅវ៉ែងដែរ ។

ប៊ុនថន : បាទ!កាលហ្នឹងអ៊ំនៅជាមួយពីណាអ៊ំវរៈសេនាធំហ្នឹង?

ខុត : អនុសេនាធំ យុន មិនដឹងគាត់ម៉ោពីណាផង យុនហ្នឹង ។

ប៊ុនថន : អត់ដឹងគាត់ម៉ោពីណាទេ?

ខុត : អត់ទេ ។

ប៊ុនថន : អ៊ំរត់សំបុត្រពីណាទៅណាអ៊ំ?

ខុត : ខ្ញុំគេឲ្យរត់សំបុត្របាយម៉ោ សរសេរយកម៉ោដាក់កងវរយអញ្ចឹងម៉ោ ទៅម៉ោៗត្រឹមហ្នឹងតែប៉ុនហ្នឹងរួចជីវិតនិរសាហើយ ។

ប៊ុនថន : ពីភូមិឬពី?

ខុត : ពីកន្លែងដូចថាមេវរៈយើងនៅនេះ អញ្ចឹងគេសរសេរសំបុត្រទៅឲ្យអនុសេនាធំអញ្ចឹងហើយខំអប់រំខំអីអញ្ចឹងទៅ មើលសភាពការណ៍ម៉េចៗអីៗទៅអញ្ចឹងទៅមានតែអញ្ចឹង ទេ

ហើយរត់ទៅឆ្ងាយណាស់ ព្រៃរមាសគេចុះចេញអស់ហើយ មិនដឹងទៅណាអស់ស្ងាត់ឈឹង ។

ប៊ុនថន : បាទ! ហើយអ៊ំអត់មានផ្លាស់ទៅកន្លែងអនុសេនាធំទេ?

ខុត : ហ្នឹងអើយ ខ្ញុំវៃទាល់តែ វៃបានមួយខែជាងហ្នឹងបានគេដក ឈ្នះ ដល់ពេលយើងឈ្នះ យើងនៅប្រចាំនៅហ្នឹងទៀត នៅផ្លូវកាតង់ ។

ប៊ុនថន : នៅផ្លូវណា?

ខុត : នៅផ្លូវកាតង់ គេហៅផ្លូវនៅជិតត្រពាំងក្រឡឹងអីហ្នឹង នៅហ្នឹងបានចំនួន៣ខែបានគេដកមកព្រំដែនយួន ដកមកខ្ញុំមកទៀត ហើយគាត់នៅឡើងមកបានធ្វើអនុវរៈហ្នឹងគេ ដែរ ដល់ពេលបានធ្វើអនុវរៈទៅ យួនបាញ់ផាប់នៅជិតនៅភ្នំជម្រុកមាន់ ។

ប៊ុនថន : គាត់ស្លាប់?

ខុត : ហ្នឹងហើយ អញ្ចឹងគេដកខ្ញុំមកទៀត គេសុំមកនៅកងកាំភ្លើងធំ កាលហ្នឹងខ្ញុំនៅតូច នៅរែកបាយស្ទុកឲ្យគេទៀតរហូត ។

ប៊ុនថន : ពូមកនៅខាងកាំភ្លើងធំវិញ?

ខុត : ហ្នឹងហើយ ។

ប៊ុនថន : កាលហ្នឹងនៅជាមួយពីណាអ៊ំ?

ខុត : កាំភ្លើងមែន?

ប៊ុនថន : បាទ!

ខុត : នៅជាមួយ តាចឹម តែគាត់ស្លាប់បាត់ហើយ កើតអេដស៍ ។

ប៊ុនថន : អ៎! គាត់ស្លាប់យូហើយ?

ខុត : ស្លាប់យើងកាលឆ្នាំ២០០២ ដៃគូជាមួយ តាសៀក អីហ្នឹង ស្លាប់អស់ហើយព្រោះកើតអេដស៍ កាលសាមារណកម្មដំបូងឃើញភ្លើងពណ៌ គ្មានខ្វល់អីទេ ដល់ពេលមកដល់ហ្នឹងមក ដល់ពេលមកដល់ភ្នំពេញអញ្ចឹងហើយ ខ្ញុំក៏មកតាមគេមក ។

ប៊ុនថន : មកជាមួយអ្នកណាគេអ៊ំ?

ខុត : ខ្ញុំមកជាមួយបង តាសន នៅអន្លង់វែងណា៎ ។

ប៊ុនថន : សេរី កុសល្យ?

ខុត : មិនដឹងទេ ។

ប៊ុនថន : ស្អី សល្យ?

ខុត ៖ អត់ស្គាល់ឈ្មោះគាត់ផង ព្រោះយើងមិនយកចិត្តទុកដាក់រៀនឈ្មោះផង ។

ប៊ុនថន ៖ ពេលបែកហ្នឹងអ៊ំមានបានចូលម៉ោភ្នំពេញទេអ៊ំ?

ខុត ៖ ខ្ញុំបានអីម៉ោភ្នំពេញ នៅកំពង់ស្ពឺហ្នឹង គេបង្ខាំងឲ្យនៅការពារផ្លូវហ្នឹងរហូតក្នុងកងហ្នឹង ស្អីៗក៏មិនឲ្យគ្នាស៊ី ដល់នេះបានគេឲ្យម៉ោព្រំដែកយួនអរៗ ដឹងតែស្រុកយួនសំបូរត្រីស៊ី ហើយព្រំប្រទល់ ។

ប៊ុនថន ៖ បាទ!ទៅខាងណាវិញខាងទល់ដែនអ៊ំ?

ខុត ៖ ក្នុងសំបុកមាន់នោះ ។

ប៊ុនថន ៖ នៅក្នុងស្រុកអីវិញអ៊ំ?

ខុត ៖ មិនដឹងស្រុកអីទេ ស្រុកយួនហើយ សំបុកមាន់ហួសស្រុកយួនបន្តិចហើយ ។

ប៊ុនថន ៖ នៅខាងខ្មែរយើង?

ខុត ៖ នៅខាងខ្មែរ ប៉ុនទៅវៃស្រុកយួន ។

ប៊ុនថន ៖ បាទ!ប៉ុននៅព្រំដែនខាងតាកែវប្អូខាង?

ខុត ៖ ហ្នឹងហើយនៅព្រំដែនយើងតាម អាហ្នឹងដូចជិតចំតាកែវដែរអាក្នុងសំបុកមាន់ហ្នឹង វា ដូចចែកជាពីរ អាមួយម៉ោព្រៃឈូកម៉ោសំបុកមាន់អញ្ចឹងម៉ោ លុងប៊ិនចេះម៉ោ ។

ប៊ុនថន ៖ លុងប៊ិន?

ខុត ៖ បាទ!ស្គាល់លុងប៊ិនទេ?

ប៊ុនថន ៖ បាទ!ខ្ញុំឮប៉ុនមិនដឹងថាទីតាំងនៅជាប់ស្រុកណាអ៊ំ?

ខុត ៖ អាហ្នឹងតាមហ្នឹងទៅតំណរក្រោម ។

ប៊ុនថន ៖ អូ!ខេត្តកណ្តាលអ៊ំ?

ខុត ៖ ខេត្តកណ្តាល ស្រុកតំណរក្រោម ប៉ុនយើងនៅថ្មុកពោតទៅនោះទៀត ហួសហ្នឹងឆ្ងាយ ទៀត ។

ប៊ុនថន ៖ បាទ!តាមផ្លូវជ្រៃធំហ្នឹងអ៊ំ?

ខុត ៖ មិនដឹងតាមណាខ្ញុំអត់ស្គាល់ដែរ ។

ប៊ុនថន ៖ អាហ្នឹងជិតជ្រៃធំ?

ខុត ៖ អត់ដែលបានម៉ោក្រោយទេ អត់មានម៉ោក្រោយអីបន្តិច សុំគេម៉ោផ្ទះក៏គេមិនឲ្យម៉ោ ។

ប៊ុនថន ៖ អ៊ំនៅហ្នឹងគេមានបែងចែកកងថ្មីទេ ពេលបញ្ជូនទៅនោះ?

ខុត ៖ គេបញ្ជូនទៅបែកកងថ្មីគេឲ្យខ្ញុំទៅចូលមេហ្នឹង គេឲ្យកាន់កងហារ កងពិសេស ហើយខ្ញុំហ្នឹងនៅធ្វើនិរសាគេទៀតទៅ ។

ប៊ុនថន ៖ និរសាឈ្មោះពូអីអ៊ំនិយាយមិញ?

ខុត ៖ និរសាគេប្រែឈ្មោះអស់អីដឹង ពីដើមគាត់ឈ្មោះហេង ។

ប៊ុនថន ៖ ស្អីហេងអ៊ំ?

ខុត ៖ អត់!ឈ្មោះ ហេង ពីដើមគេអត់យកជីតាយកអីផង ។

ប៊ុនថន ៖ បាទ!ឈ្មោះហេងហ្មង?

ខុត ៖ ឈ្មោះ ហេង ស្រុកកំណើតគាត់ៗថានៅខេត្តក្រចេះនោះ ។

ប៊ុនថន ៖ អូ!នៅខាងក្រចេះវិញ?

ខុត ៖ ហ្នឹងហើយ ប៉ុនគាត់កូនកំព្រាអត់ម៉ែ អត់ឪ គាត់ចេះតស៊ូនៅជាមួយយាយ យាយគាត់ម៉ោហ្នឹងដែលហ្នឹង ពូគាត់និយាយអញ្ចឹង ។

ប៊ុនថន ៖ បាទ!កាលហ្នឹងគាត់ឡើង?

ខុត ៖ គាត់ឡើងប្រធានអនុសេនាតូច ខ្ញុំនៅនិរសាទៀត ។

ប៊ុនថន ៖ អញ្ចឹងអ៊ំនៅនិរសាអនុសេនាតូចទៀត?

ខុត ៖ និរសាររហូតទល់ម៉ោឡាវនេះ អាឡាវស្ពាយអង្ករឲ្យទៀត ឲ្យគាត់ហូបទៀត ប៉ុនដល់ បាញ់យួនបាញ់ដកស្លាបខ្ញុំនៅខាងក្រោយនេះ ទ័ពគេឲ្យយើងទៅយកការ ស៊ើបការនៅម្តុំយើងជាំសាមជាំអីហ្នឹង បាញ់ចោលខ្មោចហ្នឹងពីណាយកអស់ ស្លាប់គាត់អញ្ចឹងទៅ គេដកយើងម៉ោទៀតម៉ោ គេដកម៉ោអន្លង់វែងទៅកងហ្នឹង ហើយគេរើសកុមារក្មេងៗជំទង់ៗអត់ប្រពន្ធម៉ោនេះកោះកុង ដល់យកម៉ោកោះកុងម៉ោក៏គេឲ្យយើងទទួលកងការពារដឹកជញ្ជូនទៀតម៉ោ ខ្ញុំក៏ជញ្ជូនគ្រាប់តែប៉ុនហ្នឹងព្រំប្រទល់ម៉ោអញ្ចឹងរហូតម៉ោ ជីវិតវាមិនថ្ងៃមិនបានធ្វើមេគេទេ ។

ប៊ុនថន ៖ បាទ!អ៊ំអាចរៀបរាប់បានបែកភ្នំពេញក្លាម ខាងអ៊ំហ្នឹងគេរៀបចំម៉េចវិញអ៊ំ?

ខុត ៖ អូ!បែកភ្នំពេញក្លាមខ្ញុំអត់បានដឹងផង ខ្ញុំនៅនេះនោះប្រហែលពីភ្នំពេញទៅត្រពាំងក្រឡឹងឆ្ងាយណាស់ ដល់អញ្ចឹងសភាពការពីភ្នំពេញអីៗអត់ដែលដឹងទេ គេមិនដែលនិយាយគេមិនដែលដឹងផងបើយើងគ្នាប៉ុន្មាន វរៈសេនាធំមានគ្នាប្រហែល១១០នាក់ គ្មានធ្វើអីនៅការពារហ្នឹងរហូត ហើយជំនាន់ស្អីនេះហ្នឹងគេដកហូតមិនឲ្យណា៎ ហើយម៉ាវយៈហ្នឹង ម៉ាយ៉ាហ្គេចាប់ម៉ោណា ។

ប៊ុនថន ៖ អូ!អ៊ំដឹងរឿងហ្នឹងដែរអ៊ំ?

ខុត ៖ ហ្នឹងហើយពួកគេថាសមុទ្រហ្នឹង ។

ប៊ុនថន ៖ ពួថាចាប់កប៉ាល់ម៉ាយ៉ាហ្គេហ្នឹង?

ខុត ៖ ហ្នឹងហើយរបស់អាមេរិចហ្នឹង ពួកគេថាអញ្ចឹង អញ្ចឹងគេចាប់យើងនៅហ្នឹងទៀតទៅ ។

ប៊ុនថន ៖ យ៉ាំងម៉េចបានមានរឿងហ្នឹងគេឃាត់នៅហ្នឹងទៀត?

ខុត ៖ គេថាការពារតាមផ្លូវ ដងផ្លូវ ហើយជិនាន់ហ្នឹងសុំគេម៉ោផ្ទះ គេថាអត់ទាន់មានច្បាប់ទៅទេអូនអើយចាំឲ្យស្រួលសិនទៅ ទៅអញ្ចឹងមិនស្រួលរញ៉េករញ៉ាក ខ្ញុំថារញ៉េករញ៉ាកម៉េច?

ប៊ុនថន ៖ កប៉ាល់ម៉ាយ៉ាហ្គេហ្នឹងអ៊ំដឹងតាមរយៈពីណាវិញអ៊ំ?

ខុត ៖ រយៈអ្នកនេះហ្នឹង ចេញចូលអ្នករត់ម៉ោពីនេះហ្នឹងរត់ម៉ោពីកំពង់សោម មាត់សមុទ្រ ។

ប៊ុនថន ៖ បាទ!ហើយកប៉ាល់ម៉ាយ៉ាហ្គេហ្នឹងរបស់អាមេរិចអ៊ីចុះ?

ខុត ៖ របស់អាមេរិច ។

ប៊ុនថន ៖ មានខាងកងទ័ពយើងចាប់ ហើយមានអាមេរិចម្នាក់គ្រាប់បែកហ្នឹង?

ខុត ៖ ហ្នឹងហើយដូចអូនថាអញ្ចឹង ។

ប៊ុនថន ៖ ហើយមានកងទ័ពយើងមួយចំនួនម៉ោពីនោះ?

ខុត ៖ កងទ័ពយើងខ្មែរហ្នឹង?

ប៊ុនថន ៖ បាទ!

ខុត ៖ ហ្នឹងហើយហែលទឹកហ្នង ដល់អញ្ចឹងខ្ញុំមិនដឹងដែរ យើងមានអីទៀតអត់ យើងនៅនេះគ្រាន់តែនាំគ្នានៅម៉ារស់ៗទៅ កុំគិតណាទៀត យើងគិតតែទឹកបាយ ហើយដូងម៉ាគគោកនៅក្នុងភូមិ ស៊ីដឹកៗដេកហ្នឹង ។

ប៊ុនថន ៖ បាទ!អញ្ចឹងមានគេរៀបចំកងពលអីទេអ៊ំ?

ខុត ៖ នៅទេអត់ទាន់ទេ កងណានៅកងហ្នឹងៗ ។

ប៊ុនថន ៖ បាទ!ចុះពេលវ៉ៃចូលភ្នំពេញនោះអ៊ំមានកងពលមានអីដែរអ៊ំ?

ខុត ៖ អត់ទេ!អូ៎ពេលវ៉ៃចូលភ្នំពេញយើងនៅកងភាគ ប៉ុន្តែភាគគេដកម៉ោនៅនេះ ប៉ុនគេយកបញ្ចូលថាកងភាពហើយ ស្អែកចូលវ៉ៃ ចូលវ៉ៃគេដកម៉ាអនុសេនាធំពួកខ្ញុំវានៅតូចៗណាំហើយគេនាំគ្នាទៅៗ ។

ប៊ុនថន ៖ បាទ!កាលហ្នឹងភាគណា ភាគនិរតីឬក៏ភាគបញ្ចឹម?

ខុត ៖ ភាគនិរតី ចូលទៅវៃបញ្ចឹម ។

ប៊ុនថន ៖ បាទ!ខាងពីណាអ្នកកាន់ខាងភាគអី?

ខុត ៖ ភាគនិរតី?

ប៊ុនថន ៖ បាទ!

ខុត ៖ មានតែតាម៉ុកហ្នឹង ។

ប៊ុនថន ៖ បាទ!និយាយខាងកងពល ៗ ភាគ?

ខុត ៖ កងពលភាគអត់ ខ្ញុំអត់ដែលស្គាល់ទេ យើងអត់ដែលបានទៅជិតផង ព្រោះមិនដឹងមនុស្សនៅណាផង ឮសូរតែកងពល ៗ សូម្បីតែវរៈសេនាធំក៏ខ្ញុំអត់ដែលស្គាល់ អត់ដែលបានចូលផង ។

ប៊ុនថន ៖ ចុះដោយសារគេដកអីទុកនៅនោះ ដោយសារអីក្មេងពេក?

ខុត ៖ វាមិនក្មេងពេកទេ ចាស់ដែរប៉ុនយើងមិនសូវគិតរវីរវល់អញ្ចឹង ៗ ទេ អ៊ីធម្មតាយុចជនមិនសូវរវីរវល់អី ឲ្យទៅណាយើងទៅហ្នឹងហើយ យើងចេះតែពីធ្វើទៅខ្លាចគេសម្លាប់អីទៅយ៉ាងម៉េចទៅ ។

ប៊ុនថន ៖ ចុះអីថាបានឡើងវៃដែរ បែកមួយព្រឹកដែរ កាលបែកភ្នំពេញអី?

ខុត ៖ កំពង់ស្ពឺបន្តិចហ្នឹង ម៉ោងព្រឹកម៉ោង៧ហ្នឹង ឡើងវៃបានម៉ោជ្រោលហ្នឹង ។

ប៊ុនថន ៖ វៃចូលខេត្តកំពង់ស្ពឺហ្នឹង?

ខុត ៖ ហ្នឹងហើយ កំពង់ស្ពឺទៅចរចារគ្នាឈប់ទៅថ្ងៃ១៧នេះ ។

ប៊ុនថន ៖ បាទ!

ខុត ៖ រៀបកងហ្នឹងទីមរៀបបាន៣ថ្ងៃហ្នឹង ។

ប៊ុនថន ៖ បាទ!កាលហ្នឹងមេដដែលអី?

ខុត ៖ មេដដែល ប៉ុនទៅអស់ហើយស្លាប់អស់ហើយ ។

ប៊ុនថន ៖ ដល់ពេលបែកភ្លាម បែកចរចារហើយហ្នឹងអីនៅឈរជើងហ្នឹងដដែល?

ខុត ៖ ឈរជើងបាន៣ខែ ។

ប៊ុនថន ៖ បាន៣ខែបានដកម៉ោ?

ខុត ៖ ដកម៉ោការពារនៅព្រំដែន ។

ប៊ុនថន ៖ នៅព្រំដែនខាងអមសំណរ ខាងអីនេះ?

ខុត ៖ ហ្នឹងហើយខាងអមសំណរ ខាងភ្នំសំបុកមាត់អីណា ពាសទឹកពាសដីនោះ ។

ប៊ុនថន ៖ អ៊ំម៉ោហ្នឹង ដកម៉ោទាំងមេអ៊ំ?

ខុត ៖ ម៉ោតែអនុសេនាធំ ប្រជុំកងគេផ្សេងៗគេ មិនមានម៉ោតែម៉ាកងយើងការពារឈ្នះទេ មានកងគេនេះ មានកងពលគេនោះអញ្ចឹងទៅ គេមិនទាន់រៀបចំដាក់កងពលអីផងនោះ នៅអនុសេនាធំលេខ១ដដែលហ្នឹង គេមិនទាន់ប្រកាសឲ្យយើងដឹងផងហ្នឹង ក្រែងគេប្រកាសគេមិនទាន់ប្រាប់យើង ។

ប៊ុនថន ៖ បាទ!ចុះតាមកងពលផ្សេងៗអ៊ំមានស្គាល់ទេ ដូច?

ខុត ៖ អត់!ខ្ញុំមិនសូវយកចិត្តទុកដាក់ផងរឿងចឹងៗ កងពលផ្សេងៗខ្ញុំស្គាល់ជាងគេតែ បង យុង នេះមួយគាត់គ្មានអីទេ គាត់ពីដើមគាត់ធ្វើវរៈសេនាធំ គាត់មឹសៗដែលហ្នឹងដល់គេចាប់គាត់ៗក៏មិនអ្នកធូរធារដូចគេទេ ហើយខុសពីហ្នឹងអត់មានអ្នកណាទៀត ។

ប៊ុនថន ៖ បាទ!ចុះអ៊ំមាននៅខាងអមសំណរហ្នឹងដូចជាមាននៅ?

ខុត ៖ កងពល?

ប៊ុនថន ៖ បាទ!មានដូចថាវៃគ្នាជាមួយវៀតណាមអីទេអ៊ំ ដូចថាប៉ះគ្នាទេ?

ខុត ៖ អមសំណរអត់ទាន់បានវៃទេ ។

ប៊ុនថន ៖ ចុះសំបុកមាន់?

ខុត ៖ សំបុកមាន់វៃដែលហ្នឹង ។

ប៊ុនថន ៖ វៃខ្លាំងទេអ៊ំ?

ខុត ៖ ល្មម វៃគ្នាមិនរបួសមិនអីផងដាក់គ្នាម៉ាព្រឹប ចុះគេមានត្រង់សេ យើងអត់ត្រង់សេ យើងទៅចូលមិនចុះ យើងងាប់ម្តង៣-៤នាក់នោះ ។

ប៊ុនថន ៖ បាទ!

ខុត ៖ ដកម៉ោវិញម៉ោ នៅតាមត្រង់សេចាស់ហ្នឹងកន្លះខែប៉ុនទៅទៀត តែឡើងទៅទៀតគេវៃទៀតហើយ ។

ប៊ុនថន ៖ បាទ!កាលហ្នឹងពីណាអ្នកដឹកនាំវៃផ្ទាល់អ៊ំ?

ខុត ៖ អ្នកដឹកនាំវៃផ្ទាល់?

ប៊ុនថន ៖ បាទ!

ខុត ៖ ឈ្មោះ សារួន យួនវៃងាប់នៅខាងលិចភ្នំសំបុកមាន់នេះ ។

ប៊ុនថន ៖ បាទ!

ខុត ៖ អាហ្នឹងពីបញ្ហាការហើយអាហ្នឹង ។

ប៊ុនថន ៖ បាទ!បញ្ហាពីណា?

ខុត ៖ កងពិសេសហើយ កងពិសេសវរៈសេនាតូច ហើយកងពិសេសផ្សេងៗទៀត ។

ប៊ុនថន ៖ វរៈសេនាតូចលេខប៉ុន្មានអីកាលហ្នឹង?

ខុត ៖ អត់ទេ!អត់មានដាក់ទេ ហើយកងគេពិសេសផ្សេងៗទៀតគេនៅកើតនោះអត់ដឹង វ៉ៃហើយបែកគ្នាៗ ដល់ពេលគេប្រជុំៗតែមេគេទៅ យើងកូននៅចាំត្រង់សេទៅ ។

ប៊ុនថន ៖ បាទ!អីឡើងវ៉ៃដែរឬជានិរសាអី?

ខុត ៖ ខ្ញុំជានិរសា យកបាយទៅ ហុចគ្រាប់ផ្លោងវីវក់ដូចតែគ្នា អស់ហើយខ្ញុំ និយាយតែប៉ុនហ្នឹងអត់មានអីនេះទៀតទេ ។

ប៊ុនថន ៖ បាទ!ហើយអីនៅរយៈពេលប៉ុន្មានអីនៅខាងសំបុកមាន់នោះ?

ខុត ៖ សំបុកមាន់?

ប៊ុនថន ៖ បាទ!

ខុត ៖ សំបុកមាន់នៅបានប្រហែលជា១ខែកន្លះបានយើងដកពីហ្នឹងម៉ោ ម៉ោវ៉ៃមិនឈ្នះមិនចាញ់អីយើងដកម៉ោក្រោយនេះម៉ោគេហៅខ្សែព្រែកៗនេះ ។

ប៊ុនថន ៖ ព្រែក?

ខុត ៖ ទៅស្រុកហ្នឹងមានស្រុកមួយ ហើយព្រែកហ្នឹងគេដាក់ខ្សែភ្លើងឆក់ទៀត តែចុះមិនស្រួលខ្សែភ្លើងឆក់ងាប់ ។

ប៊ុនថន ៖ នៅម្តុំណាវិញអី នៅជាប់ព្រំប្រទល់ខេត្តតាកែវឬខេត្តកណ្តាល?

ខុត ៖ តាកែវៗ ខ្សែព្រែកហ្នឹងវែងរហូត ។

ប៊ុនថន ៖ ព្រែកវិញគេហ្នឹងអី?

ខុត ៖ មិនដឹងព្រែកអី ព្រែកហ្នឹងវែងរហូត ម៉ោដល់កោះកុង ។

ប៊ុនថន ៖ ព្រែកជីក?

ខុត ៖ ព្រែកជីកមិនដឹង ឆ្លងព្រែកជីកហ្នឹងទៅ តាមគេនិយាយថាឆ្លងព្រែកជីកហ្នឹងទៅឆ្ងាយអញ្ចឹងទៅ ហួសវាលស្រែទៅឆ្ងាយអញ្ចឹងទៅមានទន្លេមួយធំនៅស្រុកយួននោះ អាហ្នឹងបើយើងចង់ទៅអីមោយប់ភ្លឺប៉ុនម៉ោដល់កន្លែងយើង ។

ប៊ុនថន ៖ អ្វូ!ឆ្ងាយដែលអី យើងថ្មើរជើងទៅអី?

ខុត ៖ ថ្មើរជើង យើងទៅស្ងាត់ៗហ្នឹង ខ្ញុំថាម៉ាយប់ទល់ភ្លឺងាប់ហើយ អ្នកទៅគេថាទៅម៉ាយប់ទល់ភ្លឺ ទៅឃើញផ្ទះយួនផ្ទះអីណា ។

ប៊ុនថន ៖ អ៊ំទៅប្រចាំការនៅនោះទៀតអ៊ី?

ខុត ៖ នៅណា?

ប៊ុនថន ៖ ដែលថាទៅខាងទន្លេនោះ?

ខុត ៖ អត់ទេ!អ្នកដើរ កងពិសេសគេចេះតែដើរទៅ ។

ប៊ុនថន ៖ កងពិសេសហ្នឹងម៉េច?

ខុត ៖ ដូចថាមានកន្លែងណាតូចៗល្មមវ៉ៃៗ វ៉ៃហើយម៉ោវិញម៉ោ ។

ប៊ុនថន ៖ បាទ!អញ្ចឹងអត់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នេះទេ?

ខុត ៖ អត់ទេ ។

ប៊ុនថន ៖ អញ្ចឹងគេបែងចែកយ៉ាងម៉េចទៅ?

ខុត ៖ គេបែងចែក ដូចថាពិសេសវរៈសេនាតូចអញ្ចឹង គេវ៉ៃហើយគេរាយការឲ្យវរៈសេនាធំគេម៉ោ ហើយដល់ហើយអ្នកនោះគេរាយការទៅកងពល កងពលរ៉ែន ពូឈ្មោះតែ រ៉ែនៗគេថាឈឺនៅអន្លង់វែងងាប់បាត់ហើយហ្នឹង ។

ប៊ុនថន ៖ បាទៗ!ពូឈ្មោះគាត់ គាត់អ្នកហ្នឹងប្រធានកងពិសេសអ៊ី?

ខុត ៖ ហ្នឹងហើយប៉ែកខាងត្បូង ងាប់នៅហ្នឹង អញ្ចឹងបានខ្ញុំថាងាប់អស់ហើយពួកចាស់ៗ ។

ប៊ុនថន ៖ ហើយអ៊ំម៉ោខាងនិរសាកងពិសេសហ្នឹងទៀត?

ខុត ៖ ខ្ញុំនិរសាកងពិសេសឈ្មោះ ហេងហ្នឹងងាប់បាត់ទៀត ងាប់បាត់ខ្ញុំចេះតែម៉ោតាមៗគេទៀតអញ្ចឹងទៅ រកម៉ោផ្ទះរកផ្លូវមិនឃើញ អត់ហានម៉ោ ។

ប៊ុនថន ៖ អ៊ំដកទៅកន្លែងថ្មីនោះរយៈពេលប៉ុន្មានអ៊ី?

ខុត ៖ ប្រទេសឡាវ?

ប៊ុនថន ៖ អត់ទេ អ៊ំមិញដូរកន្លែងសំបុកមាន់ទៅកន្លែងថ្មី?

ខុត ៖ កន្លះខែៗហ្នឹង មិនបានកន្លះខែផងហ្នឹងមិនសូវស្គាល់ផង វិកិលខ្សែត្រៀមទៅទៀតទៅកងគេម៉ោជួសជុលឲ្យ ហើយយើងខិតទៅទៀតទៅ ហ៎!ហើយវិកិលទៅទៀតហើយយើងវិកិលរបស់យើងតទៅទៀត អាត្រង់សេជិកហើយខឹង មានអាឯងជីកហើយរុញតែគ្នាម៉ោ គេម៉ោយកត្រង់សេឯង អាឯងនេះខំជីកហើមថ្ងាស វាអញ្ចឹង មិនបាន

ប៉ុន្មានជជឈ្នះ៧៩ក្តុង អាយើងការពារដីយើងដំបូងយើងចេះនៅដាប់ ដល់ហើយយើងចេះតែទៅត្បូង១ទៀត ។

ប៉ុនថន : ចុះមានប្រជុំមានអីទៀតទេអី ?

ខុត : អាកន្លែងត្រង់សេហ្នឹង?

ប៉ុនថន : អត់ទេឡើងម៉ោប្រជុំនៅភ្នំពេញនៅអីនេះ?

ខុត : អ៊ូ!អត់ដែលទេ អត់ដែលបានម៉ោទេ អ្នកណាគេឲ្យយើងម៉ោ ។

ប៉ុនថន : បាទ!អញ្ចឹងនៅមាំជួរនេះ មាំជួរខាងខ្សែត្រៀមព្រំដែននេះខាង អ្នកណាអ្នកគ្រប់គ្រងរួមទូទៅ?

ខុត : អត់ទេគេឲ្យកង១ហារ មេ១គេ ស្រូ ងាប់បាត់ហើយគេហៅប្រជុំ១កោះហៅប្រជុំនៅតាមត្រង់សេហ្នឹង ហៅដូចថាគ្នា ឧទាហរណ៍ដូចថាគ្នា៥នាក់អញ្ចឹង អ្នកដាំបាយនៅក្រោយអ្នកឈឺអ្នកអីខ្លះអញ្ចឹងទៅ គេហៅ២៥នាក់មាំត្រង់សេគេដាក់២នាក់១អញ្ចឹង ទៅគេឲ្យប្រយ័ត្នប្រយែងយប់ប្រលប់ដេក ប្រយ័ត្នយួនបោកគ្រាប់បែកងាប់អស់ខំការពារឲ្យមែនទែន ប្រជុំមានតែប៉ុនហ្នឹង ។

ប៉ុនថន : ចុះអត់ដែលឡើងម៉ោប្រជុំនៅភ្នំពេញទេ?

ខុត : អត់ទេ!ខ្ញុំមិនដែលស្គាល់ភ្នំពេញទេ ទឹមឆ្នាំនេះទេស្គាល់ សព្វថ្ងៃជិះឡានឲ្យទៅផ្ទះទៅរកអត់ឃើញទេ ហើយប្រាប់គេថាវោងចក្រអង្រែក្រោម១មិនដឹងនៅណាទេ មិនដឹងផ្សារដើមគរនៅណាទេ ។

ប៉ុនថន : បាទ!ហើយអឹមានខាងពីភ្នំពេញមានចុះមើលនៅតាម១ព្រំដែន?

ខុត : អត់ទេ!អត់មានឃើញចុះទេ អ្នកនៅភ្នំពេញ មានតែកងហារទេចុះឡើង កងវរយម៉ោភ្លាត១ហ្នឹង ។

ប៉ុនថន : ចុះ សុន សេនអីគាត់ដែលចុះមើលទេអី?

ខុត : អត់ដែលទេ អត់ដែលស្គាល់សុន សេនទេ ឃើញតែរូបថតហ្នឹង ។

ប៉ុនថន : បាទ!កាលហ្នឹងគាត់នៅខាងកងទ័ព?

ខុត : នៅតែភ្នំពេញនោះ គាត់ដែលចុះទៅជិតយើង ។

ប៉ុនថន : ដូចថាពេលមានវៃគ្នាអីអត់ដែលចុះទៅមើលទេ?

ខុត : អត់ទេ!អ្នកធំ១ណាទៅចុះជិត ។

ប៉ុនថន : ចុះដូចថារាយការយ៉ាងម៉េចទៅអី របៀបរាយការ?

ខុត ៖ អាហ្នឹងវាយការម៉ោតាមវរៈសេនាធំ កងពល តាវ៉ែនហ្នឹងនោះ ។

ប៊ុនថន ៖ បាទ!កងពលវ៉ែន វ៉ែនហ្នឹងកងពលលេខប៉ុន្មានអ៊ំ?

ខុត ៖ អត់មានដឹងលេខទេ លោខគាត់ជួនកាលទី២ ជួនកាលទី១ ជួនកាលទី៣ ។

ប៊ុនថន ៖ បាទ!ទី២ ទី១ ទី៣?

ខុត ៖ ហ្នឹងហើយ!អត់ដឹងលេខប៉ុន្មានទេឲ្យពិតប្រាកដ ។

ប៊ុនថន ៖ កងពលគាត់ហ្នឹងទឹមរៀបក្រោយ៧៥ហើយអ៊ំ?

ខុត ៖ កងពលហ្នឹង?

ប៊ុនថន ៖ បាទ!ក្រោយជ័យជំនះ?

ខុត ៖ ក្រោយជ័យជំនះហើយ ។

ប៊ុនថន ៖ បាទ!បន្ទាប់ពីវ៉ែន ហើយមានអីអ៊ំ?

ខុត ៖ អត់!អត់ស្គាល់ អ្ហ៊ូ!បន្ទាប់ពីវ៉ែន?

ប៊ុនថន ៖ បាទ!

ខុត ៖ គេបាញ់ចោលបាត់ហើយ គេស្ទាក់ផ្លូវបាញ់យើងនោះៗជិតក្បាលដែននោះ គេចោទថាគាត់ក្បត់ដែរ ។

ប៊ុនថន ៖ គាត់ឈ្មោះអ៊ំ?

ខុត ៖ ឈ្មោះ ភាៗ ។

ប៊ុនថន ៖ អី ភា អ៊ំ?

ខុត ៖ អត់ៗស្គាល់ គេបាញ់ងាប់បាត់ ។

ប៊ុនថន ៖ ចុះក្រោយពី ភា ម៉ោមានអ្នកណាទៀតអ៊ំ?

ខុត ៖ អត់ដឹង មានតែប៉ុនហ្នឹងទេ ។

ប៊ុនថន ៖ ចុះ វ៉ែន ហ្នឹងស្លាប់ឆ្នាំណាអ៊ំ?

ខុត ៖ វ៉ែន ស្លាប់ឆ្នាំ ៨៣ មើល៍ ៨០-៨២ជិត៨៣ហើយ ស្លាប់នៅអន្លង់វែង ប្រពន្ធយំហូរហោមដូចស្អីអញ្ចឹង ។

ប៊ុនថន ៖ ស្លាប់ដោយសារអីអ៊ំ?

ខុត ៖ ជំងឺ ផឹកស្រាច្រើនពេក ។

ប៊ុនថន ៖ គាត់ចាស់ដែរ?

ខុត ៖ ល្មមដែរ ៦០ឆ្នាំជាងហើយ ស្លាប់តាមមើល៍ផឹកស្រាច្រើនពេក ។

ប៊ុនថន : អញ្ចឹងខាងម៉ាដួរនោះ ខាងវ៉ែនអ្នកគ្រប់គ្រងអ៊ំ?

ខុត : ម៉ាដួរមុខហ្នឹង?

ប៊ុនថន : បាទ!

ខុត : ហ្នឹងហើយគ្រប់គ្រង គាត់គ្រប់គ្រងបានបន្តិច គេដកគាត់ពីកងពលទៅ គេចេញពីកងពលទី១ម៉ោ ម៉ោទី២ ម៉ោរៀបចំហ្នឹងវ៉ៃអីណាៗ ។

ប៊ុនថន : ចុះអ៊ំៗនៅនិរសាកងពិសេសហ្នឹងរហូត មានដូរឬអត់?

ខុត : អត់ទេ!គេយកម៉ោរហូត ម៉ោនៅនេះទៀតគេយកឲ្យធ្វើនិរសាទៀត ។

ប៊ុនថន : និរសានៅណាវិញអ៊ំ?

ខុត : និរសាយើងម៉ោតាមហ្នឹងរហូតម៉ោដល់នេះ បានគេឲ្យធ្វើមេក្រុមនិរសាដឹកជញ្ជូននេះ នៅមេក្រុមគេ ហើយមេក្រុមហ្នឹងជួនខ្លះខ្ញុំកើតជំងឺ គ្មានសូវបានដើរផងហ្នឹង ។

ប៊ុនថន : បាទ!

ខុត : ឬសដូងបាតនេះ ចាប់តាំងពីឆ្នាំ៨០នោះហ្នឹងនៅតែដុះ ។

ប៊ុនថន : បាទ!អ៊ំចុះពេលវៀតណាមវាយចូលម៉ោហ្នឹងអ៊ំនៅណាវិញអ៊ំ?

ខុត : ពេលវៀតណាមវ៉ៃម៉ោភ្លាមហ្នឹង?

ប៊ុនថន : បាទ!វ៉ៃម៉ោភ្លាម?

ខុត : ខ្ញុំនៅ គេនាំទៅនេះនោះហ្នឹង ខ្ញុំថាដើរៗទៅភូមិភាគកណ្ដាលអញ្ចឹងទៅ ទៅឡាវនោះ ចេះតែទៅ នាំគ្នាផ្សងព្រេងទៅ ។

ប៊ុនថន : បាទ!អ៊ំចេញពីណាទៅអ៊ំ?

ខុត : ចេញពីយើងភ្នំក្រហុកថ្មនេះទៅ ចេះតែទៅហើយគ្នាប៉ុន្មាន២-៣រយនាក់ចេះតែតាមគេទៅ ។

ប៊ុនថន : ប៉ុន្មាននាក់អ៊ំ?

ខុត : គ្នាទាំងអស់៣០០នាក់ ។

ប៊ុនថន : អាហ្នឹងអ៊ំជាអ្នកដឹកនាំទៅ?

ខុត : ខ្ញុំ?

ប៊ុនថន : បាទ?

ខុត : អត់ទេ!គេ ប៉ុន្តែខ្ញុំចេះតែទៅតាមគេទៅ ។

ប៊ុនថន : កាលហ្នឹងពីណាអ្នកដឹកនាំទៅអ៊ំ?

ខុត ៖ អ្នកដឹកនាំទៅហ្នឹង?

ប៊ុនថន ៖ បាទ!?

ខុត ៖ ឈ្មោះ ឃួន ប៊ុនហេង ប៉ុនឥឡូវបាត់ហើយមិនដឹងនៅស្រុកណាទេ វានៅរតនៈគីរីគេកៀងយកទៅ ។ នាំគ្នាទៅស្រុកនៅនោះព្រោះព្រៃច្រើន ឃួន ប៊ុនហេងហ្នឹង ។

ប៊ុនថន ៖ បាទ!ឃួន ប៊ុនហេង គាត់កាន់អីវិញអ៊ំ?

ខុត ៖ គ្នា៣០០គាត់យកគ្រប់គ្រងទាំងអស់ ពីដើមនៅពួកខាងរោងចក្រកៅស៊ូហ្នឹង ប៉ុនគេចាស់គេទុំគេថាមានស្រីអីអញ្ចឹងទៅតស៊ូទៀត ទៅតាមគេទៅហ្នឹងអត់មានអីទៀត យើងចេះតែចាស់ៗយើងចេះតែនាំគ្នាម៉ោឡាវទៀតម៉ោ ម៉ោបាយឡាវបាយអីស៊ីទៀតម៉ោភូមិឡាវ ។

ប៊ុនថន ៖ អញ្ចឹងកាលហ្នឹងម៉ោចូលទឹកដីឡាវម៉េងអ៊ំ?

ខុត ៖ ឡាវ ។

ប៊ុនថន ៖ ប៉ុនខាងឡាវហ្នឹងគេម៉េចដែរ?

ខុត ៖ ឡាវមានទាហានមានអី ឡាវមានកងទ័ពគេដែរ សុំបាយសុំអីគេរស់ទៅ នៅការពារមុខគេហ្នឹងឯង ឡាវនៅក្រោយទៀតទៅ ហើយយួនមានដែលចូលទៅដល់ឡាវណាអត់ យើងនៅម្ខាង គេឲ្យយើងនៅខាងទន្លេល្ពៅហ្នឹង នៅខាងដូចថាទន្លេហ្នឹងវាម៉ោត្បូង គេនៅខាងជើង យើងនៅខាងត្បូងម៉ោ នៅម្ខាងម្នាក់ម៉ោ គេឲ្យបាយយើងស៊ីមិនអត់ទេ លួមៗម៉ាឆ្អែតគេ ។

ប៊ុនថន ៖ អញ្ចឹងពេលទៅដល់នោះ ហេងប៊ុនធី ហ្នឹងលែងឲ្យអ៊ំនេះ ឲ្យអ៊ំមើលខុសត្រូវ?

ខុត ៖ អត់រលីងនៅតែដដែល ខ្ញុំនៅមេគេអញ្ចឹងរហូត ។

ប៊ុនថន ៖ ចុះអ៊ំថាដឹកនាំកម្លាំងម៉ោជាមួយខាងនេះនោះ ខាងចូលម៉ោខាងអន្លង់វែងខាងអីនោះ?

ខុត ៖ អ៊ូ!ដឹកនាំហ្នឹងគេអ្នកដឹកនាំ ប៉ុនខ្ញុំម៉ោជាមួយគេហ្នឹង គេមិនឲ្យខ្ញុំជាអ្នកដឹកនាំទេ ចេះនាំគ្នាដឹកនាំម៉ោជាមួយគេ តាំងគេទាំងខ្ញុំចេះតែនាំគ្នាម៉ោៗទៅណា អាតូចអាតាចអីចេះតែប្រមូលទៅ ។

ប៊ុនថន ៖ បាទ!ចុះពេលទៅដល់នោះគេបែកចែកម៉េចវិញអ៊ំ ពេលទៅដល់ឡាវនោះ?

ខុត ៖ ម៉ោដល់ណា?

ប៊ុនថន ៖ ដូចខាងអ៊ំថាខាងទន្លេល្ពៅអីគេបែងចែក?

ខុត ៖ ម៉ៅទន្លេល្អៅគេអត់ថាអីយើងទេ គេថាអ្នកគស៊ូដូចតែគ្នាៗ នៅបាយ នៅទឹកហ្នឹងជាមួយគ្នាអញ្ចឹងទៅ បាយទឹកគេឲ្យយើងនៅលើភ្នំ យើងអ្នកអត់ស្គាល់ភូមិសាស្ត្រដូចគេ គេសុទ្ធតែអ្នកស្រុកនោះ ។

ប៊ុនថន ៖ បាទ!

ខុត ៖ ចុះទៅក្រែងល៉ឺយួនវៃយួនអីបែកគ្នា ឆាប់អស់ ។

ប៊ុនថន ៖ បាទ!អញ្ចឹងនៅលើភ្នំនោះ?

ខុត ៖ នៅលើភ្នំ ។

ប៊ុនថន ៖ ចុះនិយាយថាយើងមានទាក់ទងគ្នាទេអីកាលហ្នឹង ទាក់ទងគ្នាជាមួយតំបន់គេផ្សេងៗ ទៀត?

ខុត ៖ មិនដឹងម៉េចគេ គេឲ្យទៅណាយើងចេះតែទៅគេទៅ រឿងទាក់ទងយើងមិនខាងបានចូលទេជិនាន់ហ្នឹង អត់មានអ្នកណាបានចូលទេ ហើយម៉ោអញ្ចឹងទៀតម៉ោក៏គេខបត្តមទៀតម៉ោព្រោះគេនៅតែលើរហូតហ្នឹង ។

ប៊ុនថន ៖ ខាងណាខបត្តមវិញអឹ?

ខុត ៖ ម៉ោអញ្ចឹងម៉ោ កងពលតាភាព ពោះអាចម៉ធំស្លាប់បាត់ឆ្នាំ៨០ ហ្នឹងមានតែតាភាពហ្នឹងមួយទេ ។

ប៊ុនថន ៖ អីភាពគាត់ហ្នឹងអឹ?

ខុត ៖ អត់ស្គាល់ម៉ោពីដើមទឹក អាហ្នឹងគេខបត្តមអញ្ចឹងម៉ោបាយទឹកអញ្ចឹងម៉ោ បានជារើសកងក្មេងៗ ម៉ោនេះទៀតម៉ោ ។

ប៊ុនថន ៖ អញ្ចឹងកងអីហ្នឹងមានចេញពីហ្នឹងម៉ោទៀតទេអឹ?

ខុត ៖ នៅហ្នឹងខ្លះ ចេញសុទ្ធតែអ្នកនៅលើវៗទេ ចាស់ៗគេទុកនៅហ្នឹងទាំងអស់ ។

ប៊ុនថន ៖ បាទ!អញ្ចឹងអឹម៉ោជាមួយគេទេអឹ?

ខុត ៖ សុំគេម៉ោទៀត ។

ប៊ុនថន ៖ ម៉ោដំបូងហ្នឹងម៉ោនៅណាអឹ?

ខុត ៖ ដំបូងសុំគេមៅថាម៉េចរកផ្លូវម៉ោផ្ទះ ដំបូងខ្ញុំម៉ោនៅនេះចំការល្ហុងដីថៃគេយកម៉ោដាក់ហ្នឹង ។

ប៊ុនថន ៖ ចុះអឹថាទៅជាំក្សានទៀតអឹ?

ខុត ៖ អ៊ូ!អាហ្នឹងផ្លោះហ្នឹង ម៉ោហ្នឹងម៉ោមិនជាំក្សាន ទន្លេល្អៅហ្នឹង ហើយយើងម៉ោទៀតមិនអន្ទង់វែងៗ ហើយមិនម៉ោអូរល្ហុងតែប៉ុនហ្នឹង ។

ប៊ុនថន : អីថារូមគ្នាទៀតនោះ មានទ័ពរួមគ្នាទៀតនោះ ?

ខុត : ទ័ពរួមគ្នាហ្នឹងនៅអូរល្ហុងនេះ ។

ប៊ុនថន : អូរល្ហុងនៅដីថៃឬដីខ្មែរអី?

ខុត : ដីថៃ ថៃអត់នៅប៉ុនខ្មែរដេញចេញអស់ អូរល្ហុងហើយបានទល់សមាហរណកម្មហ្នឹង កងដឹកជញ្ជូនគេរហូតហ្នឹង ។

ប៊ុនថន : អូរល្ហុងហ្នឹងខាងណាគ្រប់គ្រងវិញអីកាលហ្នឹង?

ខុត : អូរល្ហុងយើងនេះ មិននោះទេណា៎ ។

ប៊ុនថន : នៅខាងណាវិញ?

ខុត : ជិតកោះកុងនោះ ។

ប៊ុនថន : ជិតកោះកុង?

ខុត : បាទ!មានស្ទីទេគាត់អ្នកគ្រប់គ្រងដឹកជញ្ជូនជាមួយតាបារាំង១ ប៉ុនយួនចុចរាប់បាត់ ហើយមេកងដឹកជញ្ជូន ហើយតាសេងនោះកើតទាច...ទាចអីជំងឺលើសឈាមស្លាប់បាត់ យើងពឹកពឿននៅឆ្នាំប៉ុន្មានទេ ខ្ញុំម៉ោនេះហើយ ។

ប៊ុនថន : ចុះអីម៉ោខាងនេះអីគេឲ្យអីម៉ោខាងដឹកជញ្ជូនវិញ?

ខុត : ហ្នឹងហើយ!បើមេក្រុមខ្ញុំនេះនៅតែផ្ទះគ្មានធ្វើអី បើកើតឬសដូង ស្ពាយណារួច ស្ពាយចេញឈាម១ហើយអត់បានធ្វើអីទេ ។

ប៊ុនថន : បាទ!កងដឹកជញ្ជូនតែនារីអី ឬក៏មានបុរសដែរ?

ខុត : នារីក៏មាន បុរសក៏មាន បុរសការពារ ។

ប៊ុនថន : ហ្នឹងគេជ្រើសរើសតែអ្នកនៅលីវឬក៏មានគ្រួសារហើយ?

ខុត : មានក្នុងស្រុកនេះគេមាន នារីប្រហែល៤០០នាក់ជាងមិនតិចណា៎ ។

ប៊ុនថន : បាទ!បុរសប៉ុន្មាននាក់អី?

ខុត : បុរសជាប់ប្រហែល១០០នាក់ជាងនោះ ។

ប៊ុនថន : ទាំងអស់៥០០នាក់អី?

ខុត : ហ្នឹងហើយ ។

ប៊ុនថន : ចុះអើមានដឹកជញ្ជូនអីខ្លះអីកាលហ្នឹង?

ខុត : គ្រាប់ រំសេវ អង្ករហូបតែប៉ុនហ្នឹងឯង ។

ប៊ុនថន : បាទ!យើងដឹកពីដីថៃម៉ោឬក៏មានឃ្លាំងនៅដីខ្មែរអី?

ខុត ៖ មានតែដីកម៉ោពីដីថៃ ថៃអន្តរ គ្រាប់មិនដឹងរើសយកម៉ោពីណាជងអាខ្វះខ្វារខ្វះអីចេះ កងអូសយកម៉ោដាក់ មិនដឹងគ្រាប់គេសល់ពីជំនាន់ណាម៉ោយើងចេះតែរើសដាក់ មិនដឹងសល់ពីជំនាន់ណាវាគ្រប់ជំនាន់អាហ្នឹង ។

ប៊ុនថន ៖ បាទ!

ខុត ៖ ម៉ាជំនាន់ដកបាត់ទៅ ម៉ាជំនាន់ចូលម៉ោទៀតទៅៗ ។

ប៊ុនថន ៖ ចុះសំភារៈហ្នឹងម៉ោពីណាវិញអ៊ំ ជំនួយ?

ខុត ៖ ជំនួយមិនដឹងម៉ោពីណា ខ្ញុំអារឿងអញ្ចឹងៗខ្ញុំមិនសួរសួរគេផង អត់រវល់ព្រោះខ្ជិល ។

ប៊ុនថន ៖ មិនមែនម៉ោពីចិន ម៉ោពីអីទេអ៊ំ?

ខុត ៖ មិនដឹងម៉ោពីណា បើម៉ោតែលិច មិនដឹងថៃ មិនដឹងចិន មិនដឹងយួនអីអ្នកណា ។

ប៊ុនថន ៖ បាទ!ចុះអ៊ំម៉ាភាគខាងកោះកុងនេះ ខាងអ្នកណាអ្នកគ្រប់គ្រងរួមហ្នុង?

ខុត ៖ រួម តាមុត ហ្នឹង ។

ប៊ុនថន ៖ មាស មុត អ៊ំ?

ខុត ៖ ហ្នឹងហើយ ។

ប៊ុនថន ៖ បាទ!តំបន់ហ្នឹងចាប់ពីណាដល់ណាអ៊ំ?

ខុត ៖ អាហ្នឹងម៉ាជួរព្រំដែនឡាវហ្នឹង ។

ប៊ុនថន ៖ បាទ!ពីតំបន់ណាដល់ណា ពីខេត្តណាដល់ខេត្តណាអ៊ំ?

ខុត ៖ ពីសំឡូតយើងម៉ោកោះកុង ខ្សែលើយើងរហូតម៉ោ ។

ប៊ុនថន ៖ ពីសំឡូតម៉ោដល់កោះកុងគាត់ជាអ្នកគ្រប់គ្រងនៅហ្នឹង?

ខុត ៖ បាទ!ហ្នឹងហើយ ។

ប៊ុនថន ៖ អញ្ចឹងនិយាយថា មាស មុតកាលពីដើមគាត់ធ្វើអីវិញអ៊ំ?

ខុត ៖ មិនដឹងធ្វើអីទេចាស់ៗ តាមមើលមិនដឹងម៉ោពីណាៗទេ ខ្ញុំអត់សួរស៊ើបប្រវត្តិរូប ។

ប៊ុនថន ៖ បាទ!ចុះកាលហ្នឹងម៉េចបានប្ដូរអ៊ំម៉ោខាងដឹកជញ្ជូនវិញអ៊ំ?

ខុត ៖ ឲ្យធ្វើមេក្រុមហ្នឹង?

ប៊ុនថន ៖ បាទ!

ខុត ៖ កាលហ្នឹងខ្ញុំវាធ្វើអីអត់កើត មេកងក្រុមខ្ញុំហ្នឹង មេកងហ្នឹងគេជ្រើសរើសឲ្យខ្ញុំម៉ោធ្វើមេក្រុមកងដឹកជញ្ជូនស្បៀង ដឹកជញ្ជូនអីអញ្ចឹងទៅ ។

ប៊ុនថន ៖ កាលមុនហ្នឹងអ៊ំនៅកងម៉ោពីទន្លេល្អោ ?

ខុត ៖ អាហ្នឹងសុទ្ធតែនិរសាម៉ោរហូត ។

ប៊ុនថន ៖ បាទ!កាលហ្នឹងអ៊ំមានដឹងកងពល កងវរៈប៉ុន្មានទេអ៊ំ?

ខុត ៖ និរសានាយភឿន ។ហ្នឹងគេកាន់វរៈកាន់អនុសេនាធំ ។

ប៊ុនថន ៖ អនុសេនាធំប៉ុន្មានអ៊ំ?

ខុត ៖ កងដឹកជញ្ជូន អនុសេនាធំលេខ២ កងដឹកជញ្ជូន ។

ប៊ុនថន ៖ អ្ហូ!ស្អីភឿន អ៊ំ?

ខុត ៖ ភឿន ស្គាល់តែឈ្មោះភឿនអញ្ចឹងហ្នង ។

ប៊ុនថន ៖ គាត់នៅរស់ឬស្លាប់អ៊ំ?

ខុត ៖ គេហៅភឿនផង ហៅភឿនផង ។

ប៊ុនថន ៖ បាទ!ហើយគាត់នៅរស់ទេអ៊ំ?

ខុត ៖ អេស៎!បែកគ្នាយូរមិនដឹងទៅណាអស់ មិនដឹងដែរ ។

ប៊ុនថន ៖ បាទ!អញ្ចឹងអ៊ំនិរសារបស់គាត់?

ខុត ៖ ហ្នឹងហើយ ហើយចេញពីនិរសាហ្នឹងទៅ ខ្ញុំនៅហ្នឹងយូរៗធ្វើអីមិនកើតៗទៅណាមិន កើត ឯងមើល៎គ្រប់គ្រងតែម៉ាក្រុមហែងហ្នឹងទៅ គ្រប់គ្រងអាអ្នកឈឺអាអ្នកជាហ្នឹងចេះ តែជួយមើលគ្នាអញ្ចឹងទៅ កាលណាគេជាអស់អញ្ចឹងគេទៅៗ យើងនៅតែផ្ទះអញ្ចឹង ទៅ ចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមអីទៅ ។

ប៊ុនថន ៖ អ៊ំម៉ោខាងនារីនេះប្រមូលពីណាខ្លះម៉ោអ៊ំ?

ខុត ៖ អេស៎!មិនដឹងគេប្រមូលពីណាម៉ោ ខ្ញុំម៉ោឃើញហើយហ្នឹង ហួសកងចល័តហួសអីនោះ អ្នកតស៊ូកាលហ្នឹង ខ្ញុំមិនដឹងដែរ គេនៅយូរហើយបានខ្ញុំម៉ោដល់ហ្នឹង ។

ប៊ុនថន ៖ បាទ!ចុះអ៊ំរយៈពេលប៉ុន្មានបានម៉ោគ្រប់គ្រងខាងដឹកជញ្ជូន?

ខុត ៖ ម៉ោដឹកជញ្ជូនបានប្រហែលកន្លះឆ្នាំតាមមើល តាំងពីគេបាញ់បងខ្ញុំងាប់ម៉ោ ខ្ញុំក៏មិន រវល់នឹងរឿងអីៗណាទៀតគិតច្រើនពេកខ្ញុំខ្ជិល សុទ្ធតែបងខ្លួនឯងមិនក្បត់ផង ប្អូននោះ ធ្វើអីផងនៅតែបាញ់គ្នាងប់ទៀត បាញ់ចោលមិនបានយកខ្មោចយកបានអីទេ ដល់ អញ្ចឹងខ្ញុំលែងរវីរវល់ហើយ ខ្ញុំធ្វើអាមុខក៏មិនទៅ អាក្រោយក៏មិនទៅខ្ញុំនៅតែផ្ទះដាំ បាយ ។

ប៊ុនថន ៖ បាទ!ប៉ុនអ៊ំនៅក្នុងកងដឹកជញ្ជូនដដែល?

ខុត ៖ ដដែល នៅផ្ទះចិញ្ចឹមមាន់ ដាំស្ពៃ អត់មានជ្រូកទេ មានតែប៉ុនហ្នឹង គ្មានធ្វើអីរហូតដល់ហ្នឹងម៉ោនាំគ្នាប្រមូលគ្នាបានជិត៧-៨នាក់ហើយ សុទ្ធតែអ្នកដាច់ខាតខ្ចិលអានៅផ្ទះក៏យើងយ៉ាប់ នៅនេះក៏យើងយ៉ាប់ប្រថុយចូលមួយសារភាព ទាក់ទងកងគេហ្នឹងទៅ ព្រៃហ្នុងទៅទាក់ទងគេត្រូវរូវនាំឲ្យបាញ់យើងចោល ។

ប៉ុនថន ៖ ប៉ុនអ៊ំនិយាយថានៅតែផ្ទះអញ្ចឹង គេឲ្យធ្វើកងដដែល ដូចថាយើងអត់សូវសកម្មការងារអីអញ្ចឹង?

ខុត ៖ ប្រធានក្រុមដដែល នៅគ្នាប៉ុន្មានម៉ាក្រុមមានគ្នា១២នាក់ហ្នឹង ទាំងខ្ញុំ១២នាក់ៗចុះឡើងៗគេទៅដឹកជញ្ជូនអស់នៅសល់តែ៣នាក់ ៤នាក់នោះ សល់ប៉ុន្មានខ្ញុំថាហើយ៎ហាសសល់ប៉ុន្មានជញ្ជូនធ្វើអីទេ ងាប់ចោលម៉ែឪទេ តែមិនស្រួល ធ្វើឈឺធ្វើអីខ្លះទៅ ។

ប៉ុនថន ៖ បាទ!ហើយអ៊ំចូលសមាហរណកម្មហ្នឹង និយាយថាអ៊ំមានអ្នកទាក់ទងឲ្យចូល ឬក៏អ៊ំ នេះ?

ខុត ៖ ទៅអ្នកទាក់ទងអាងកងដែលធ្លាប់រៃជាមួយគ្នាមុនគេនៅហ្នឹងហើយហ្នឹងទៅៗ ទៅដល់សួររកគេរកអីទៅ គេពិនិត្យខោអាវពិនិត្យអីយើងទៅ ខ្ញុំគ្មានអីមានតែខោខ្លីមួយ អត់អាវទៀតទៅប្រាប់គេត្រង់អញ្ចឹងម៉ង អត់អ្នកយកការណ៍យកអីទេ ទៅដល់ខ្ញុំសុំតែរស់ ទេបើមិនឲ្យធ្វើអីនៅហ្នឹងក៏បានដែរ ព្រោះសម័យនោះគេប្រុងចាប់ខ្ញុំដាក់គុក ដាក់អី ណានោះខ្ញុំឈប់នៅទៀតនោះ អញ្ចឹងៗរហូតអញ្ចឹងម៉ោទល់ឈ្នះទៀតម៉ោ បានម៉ោ ផ្ទះហើយនេះបានអភិបាលស្រុកគាត់ឲ្យម៉ោធ្វើអីទៀតនេះ ក៏ធ្វើហ្នឹងទៀតទៅ ។

ប៉ុនថន ៖ បាទ!ចុះអ៊ំថាយកប្អូនស្រីម៉ោនោះ?

ខុត ៖ អ្ហូ!យកហ្នឹងហើយ បានគេចាប់ខ្ញុំដាក់គុក ។

ប៉ុនថន ៖ ឆ្នាំប៉ុន្មានអ៊ំ?

ខុត ៖ អាហ្នឹងឆ្នាំ៨៨ ។

ប៉ុនថន ៖ ៨៨?

ខុត ៖ អេស៎!៩៣ អាប្អូនខ្ញុំហ្នឹងថាឲ្យទៅស្រុកវិញទៅ ។

ប៉ុនថន ៖ យកម៉ោនៅណាពូកាលហ្នឹង?

ខុត ៖ ពីដើមនៅជាមួយខ្ញុំ ទៅស្រុកវិញបាត់ហើយ ។

ប៉ុនថន ៖ យកទៅនៅណា?

ខុត ៖ យកនៅចំការល្ហុងជាមួយខ្ញុំនេះ ដីថៃនេះ ពួក្មេងៗនិរសាៗគេថាឯងប្រយ័ត្នមែនទែនគេចាប់ដាក់គុកគេតាមដានខ្លាំងណាស់ តាមខ្លាំងខ្ញុំអត់ធ្វើអី ខ្ញុំឈឺឬសដូងរហូតនៅតែ ផ្ទះ

តាមហៅយើងយកទៅអប់រំទៅអប់អី មេកងហាកងអីគេហៅឲ្យអប់រំ ហើយខ្ញុំថាប្អូនខ្ញុំបង្កើតទេ ហើយខ្ញុំក្បត់ចាំតែមើលទៅ ហើយបងខ្ញុំយកឪម៉ោក៏ជាប់គុកពេលហ្នឹងទៅ២នាក់ដដែល ។

ប៊ុនថន ៖ បងយកម៉ោពីនោះជាប់គុកដែរ?

ខុត ៖ ជាប់គុកប្រហែល២ឆ្នាំ ។

ប៊ុនថន ៖ ចុះអ៊ំក្រោយពីដោះលែងអ៊ំហើយអ៊ំនៅកងដដែលអ៊ំ?

ខុត ៖ ដោះលែងហើយខ្ញុំនៅជំរុំ ។

ប៊ុនថន ៖ នៅជំរុំ?

ខុត ៖ បាទ!

ប៊ុនថន ៖ ចុះអ៊ំមានតួនាទីអីទៀតឬអត់?

ខុត ៖ អត់!មានតួនាទីអីបារាំងគ្រប់គ្រងហើយហ្នឹង ។

ប៊ុនថន ៖ អ៊ំទៅនៅជំរុំហ្នឹងខាង?

ខុត ៖ ធ្វើការខាងយូណេស្កូ ធ្វើការអន្តការ កាកបាទក្រហមគ្រប់គ្រងហ្នឹង យើងមានអីគឺទៅបើកអន្តរម្តងម្កាលទៅ គេចងខ្សែព័ទ្ធជុំវិញអញ្ចឹងទៅ កុំឲ្យអ្នកណាចេញអ្នកណាចូល យើងនៅកណ្តាលហ្នឹងទៅ ពេលយើងចេញទៅគេបើកសោរពិនិត្យឈ្មោះៗ មួយអាទិត្យបើកម្តងៗអញ្ចឹងទៅ ចេះតែបើកទៅហើយខ្ញុំកាលហ្នឹងខ្ញុំកើតជំងឺឬសដូងបាតផងគ្រុនពោះវៀនផង អញ្ចឹងធ្វើឲ្យយកទៅមើលនៅក្នុងជំរុំជាប់បានប្រហែលមួយខែជាងដែរទំរាំជា ជាម៉ោដុះដើរបបួលកូនក្មេង នៅវត្តដូចពិបាកណាស់ ។

ប៊ុនថន ៖ អ៊ំចេញសារភាពឆ្នាំប៉ុន្មានអ៊ំ?

ខុត ៖ ចេញសារភាពឆ្នាំ៩៨ ។

ប៊ុនថន ៖ ឆ្នាំ៩៨ អ៊ំសារភាពនៅណាវិញអ៊ំ?

ខុត ៖ នេះនៅសំឡូតនេះ តាមអូរល្ហុងហ្នឹងឡើងម៉ោលើ ។

ប៊ុនថន ៖ ហើយឆ្នាំប៉ុន្មានបានម៉ោនៅវាលវែងអ៊ំ?

ខុត ៖ ឆ្នាំ៩៩ ។

ប៊ុនថន ៖ គេបញ្ជូនម៉ោ ឬម៉ោ?

ខុត ៖ ម៉ោតាមបងគេឲ្យម៉ោនៅស្រុកភូមិនេះវិញ បងមេស្រុកហ្នឹង ។

ប៊ុនថន ៖ ពូ យ៉ុងហ្នឹង?

ខុត :	ហ្នឹងហើយ ឃើញគាត់ចេះអន្ទង់ៗ ហៅគ្នាម៉ោច្រើនម៉ោកុំឲ្យថានៅអីទៀត វរៗ ម៉េចម៉ា ទៅយើងកើតរឿងកើតរ៉ាវធំ យើងនៅស្រុកនេះមិនស្រួលជាងក៏ម៉ោជាមួយគាត់រហូត ម៉ោបានប្រហែលជាង១០គ្រួសារដែរម៉ោជាមួយគាត់រហូត ។

ប៊ុនថន :	ឆ្នាំ៩៩ហ្នឹង មានតែ១០គ្រួសារទេម៉ោ ។

ខុត :	គេម៉ោខាងនោះៗច្រើនចូលដូចតែគ្នា គាត់ថាខ្ញុំមានតែ១០គ្រួសារទេម៉ោ ។

ប៊ុនថន :	អញ្ចឹងមានគេម៉ោមុនអ៊ំអី?

ខុត :	អត់ទេៗ!ជំរុំហ្នឹងដល់ម៉ោៗទាំងអស់គ្នា ដឹងតែកងផ្សេងៗពីគ្នាអត់ស្គាល់គ្នា នេះក៏គេម៉ោនោះក៏គេម៉ោ នៅផ្សេងៗគ្នា ចុះជំនាន់ហ្នឹងគេឈប់នេះ គេអត់មានធ្វើអីទៀតផង អ្នកណាស្រុកកំណើតយើងនៅណាយើងទៅហ្នឹងទៅ អ្នកណាមិនចង់ទៅស្រុកកំណើតយើងម៉ោភូមិថ្មីនេះ ទៅរុករានដីថ្មីនេះយើងខំរុករានដីទៅថ្មីទៅ ហើយទៅនោះអត់សូវអង្ករហូប ។

ប៊ុនថន :	បាទ!អ៊ំនៅវាលវែងពេលដែលអ៊ំម៉ោនៅដំបូងហ្នឹងមានមនុស្សម៉ោនៅទេ?

ខុត :	ព្រៃណែនផ្អឹស អត់មានមនុស្សទេ ។

ប៊ុនថន :	សុទ្ធតែព្រៃ?

ខុត :	ហ្នឹងហើយសុទ្ធតែព្រៃ ហើយមីនទាំងអស់ ។

ប៊ុនថន :	សំបូរមីនដែលអ៊ំ?

ខុត :	មីនអ៊ូរលេខ១មីន ទឹមខាងកើងផ្ទះ យ៉ែន អូរស្លាបមាន់នេះជិត១ម៉ឺនមីននោះគរដូច ដំបូក ។

ប៊ុនថន :	១ម៉ឺនគ្រាប់?

ខុត :	បាទ!ខាងណាអ្នកដាក់ទៅកាលហ្នឹង?

ប៊ុនថន :	យួន ការពារកុំឲ្យខែរក្រហមដេញ ជំនាន់ហ្នឹងជំនាន់វៃគ្នា តាមជួរភ្នំអស់ហ្នឹង ។

ខុត :	ហើយគេបែងចែកម៉េចទៅអ៊ំ?

ប៊ុនថន :	បែងចែកម៉េច ដូចថាបែងចែកដីធ្លីអីអ្នកចូលម៉ោអី?

ខុត :	បែងចែកម៉ាគ្រួសារ៥ហិចតាៗអញ្ចឹងទៅ ប៉ុន្តែព្រៃអ្នកណាកាប់ប៉ុនហ្នឹងសិនទៅ បើគ្នាតិចអ្នកណាអត់កម្លាំងក៏កាប់ប៉ុនហ្នឹងសិនទៅ អ្នកខ្លះបាន១០ហិចតាទៅគេគ្រាន់ចែកកូនក្រោយកូនមុនចែកចៅអញ្ចឹងទៅណា៎ ។

ប៊ុនថន :	ប៉ុនមានរបបទេអ៊ំ?

ខុត :	របបអី?

ប៊ុនថន : របបដូចថាពីកន់ទ័ពអីហ្នឹង របបបើកអន្ករបើកអី?

ខុត : របបបើកអន្ករបើកអី?

ប៊ុនថន : បាទ!

ខុត : អត់ទេបើយកអន្ករពីជំរុំម៉ោហើយ ។

ប៊ុនថន : អញ្ចឹងអត់មានទេម៉ោដល់ហ្នឹង?

ខុត : បាទ!ម៉ោដល់ហ្នឹងភ្លាមអន្ករអាខ្វះដឹកបាន៥-៦ការុង ៧-៨ការុងអញ្ចឹង គេចែកពីកាកបាទនោះសល់ ហើយគ្នាយើងចូលភូមិនិវត្តន៍ម៉ោស្រុកវិញណាស់ ។

ប៊ុនថន : អញ្ចឹងម៉ោដល់នេះយើងធ្វើអីទៅ?

ខុត : យើងម្ចាស់ការលើខ្លួនឯងហើយ មានធ្វើអីកូនឈើមើលថ្នាំពេទ្យថ្នាំអីចាក់ខ្លួនឯងអញ្ចឹង ទៅគ្រប់គ្នាអញ្ចឹងទៅ អាណាខ្លាំងពេកទៅក៏យកទៅពោធិ៍សាត់ទៅ ឃើញនៅមាំ កន្ទាក់ៗអញ្ចឹងនេះកន្ទាក់ នោះកនាក់ៗតៗគ្នារហូត ។

ប៊ុនថន : ចុះរចនាសម្ព័ន្ធភូមិឃុំអីអញ្ចឹង គេរៀបចំយ៉ាងម៉េចអ៊ំ?

ខុត : អារចនាសម្ព័ន្ធមានពីលើហើយស្រេចហ្នឹង រៀបចំដូចថាខ្ញុំក្នុង១ម៉ោងអញ្ចឹងទៅហើយ ទឹមនេះ អាភូមិអន្ទង់រាបគេដាក់អីៗតាមរចនាសម្ព័ន្ធចាស់ទាំងអស់ អាភូមិចាស់ពីដើមសុទ្ធតែជនជាតិនៅ ។

ប៊ុនថន : អ្ហូ!ពីមុនម៉ោជនជាតិ ជនជាតិអីវិញអ៊ំ?

ខុត : ជនជាតិអីទេ ជនជាតិកួយ សាវាយ ។

ប៊ុនថន : សព្វថ្ងៃនេះមាននៅទេអ៊ំ?

ខុត : អេស៎!មិនដឹងនៅឬអត់ សាវាយក៏មានអីក៏មាន ។

ប៊ុនថន : ចុះអ៊ំសព្វថ្ងៃនេះជនជាតិហ្នឹងនៅរស់ទេអ៊ំ?

ខុត : ឮថានៅក្រវាញនៅអីណានោះ ខ្ញុំមិនសូវដែលឃើញផងឮគេថានៅខ្លះ ក្មេងលេងរបស់គាត់ហ្នឹងក៏ភេនជនជាតិ ចូលពោធិ៍សាត់មួនៗ ។

ប៊ុនថន : បាទ!ក្មេងអីវិញអ៊ំ?

ខុត : ក្មេងៗចាំចំណាំមើលក្នុងទូរទស្សន៍ ហ្នឹងវ៉ៃកន្ត្រក់ វ៉ៃមុង វ៉ៃត្រឡោក វ៉ៃអី ។

ប៊ុនថន : បាទ!ហើយអ៊ំម៉ោនៅនេះហ្នឹងគេបែងចែកក្រោយ ឬគេបែងចែកភូមិតាំងពីមុន ហើយ?

ខុត : អ្ហូ!ខ្ញុំនៅបានប្រហែលជា៣-៤ខែបានគេរៀបចំ ។

ប៊ុនថន : ដូចដាក់ឈ្មោះភូមិ ឃុំអី ទឹមរៀបចំក្រោយទេអ៊ំ?

ខុត ៖ អាភូមិចាស់ហ្នឹងរៀបចំភូមិចាស់ហ្នឹងយកភូមិចាស់ហ្នឹង ដដែលហ្នឹងសុំបន្តភូមិថ្មី អត់មានលាយគ្រីតចេញម៉ោយើងម៉េចហាន អញ្ជឹងយកអាភូមិចាស់ហ្នឹងទៅ ។

ប៊ុនថន ៖ បាទ!អញ្ជឹងភូមិប្រមោយ ផ្សារព្រៃ ស្ទឹងថ្មី ភូមិថ្មីតាំងពីមុនម៉ោដំបូងឬក៏ទឹមដាក់ក្រោយទេអ៊ំ?

ខុត ៖ អាស្ទឹងថ្មីនេះនៅពីមុន គាត់រនេះសុទ្ធតែពីមុន ។

ប៊ុនថន ៖ ពីមុនទេ?

ខុត ៖ ហ្នឹងហើយផ្ទះមួយ ផ្ទះពីរអី ។

ប៊ុនថន ៖ ចុះស្រុកវាលវែលនេះអ៊ំ?

ខុត ៖ វាលវែងនេះពីដើមគេហៅភូមិវាលវែង ដល់យូរៗទៅដាក់ស្រុកវាលវែងអញ្ជឹងម៉ោ អាហ្នឹងបានចែកកូនស្រុកមួយហៅស្រុកអញ្ជឹងម៉ោ ប្រជាជនជាង២ពាន់គ្រួសារអញ្ជឹងម៉ោ ។

ប៊ុនថន ៖ ចុះអ៊ំចង់សួរអ៊ំមួយទៀតមុនសមាហរណកម្ម ពីមុនស្ថានភាពមុនចុះចូលរដ្ឋាភិបាលហ្នឹងអ៊ំប្លែកយ៉ាំងម៉េចដែរអ៊ំ ជីវភាពខាងប្រកបការងាររអី?

ខុត ៖ នៅនោះជីវភាពកាលហ្នឹងបានកាកបាទចិញ្ចឹម ដល់ម៉ោដល់នេះទៀតយើងខបត្តម្ភខ្លួនយើងបានអីបានអញ្ជឹងទៅ រហូតដល់មានពេទ្យគេហៅថាពេទ្យឥតព្រំដែន ដើរម៉ោមើលចែកថ្នាំចែកអីប្រជាជនអញ្ជឹងទៅ ហើយយើងបង្កើតសុខាភិបាលតូចៗតាមភូមិមួយៗអញ្ជឹងទៅណា៎ អញ្ជឹងយើងខុសប្លែកអញ្ជឹង មិនដូចនោះទេ នោះគេមានដែរប៉ុនយើងវាឆ្ងាយៗ មើលបានដូចគ្នាអញ្ជឹងដែរ ។

ប៊ុនថន ៖ ចុះជីវភាពអីអ៊ំ?

ខុត ៖ ជីវភាពកាលម៉ោនៅអត់ទាន់យ៉ាប់យឺនអីទេ ព្រោះយើងមានអង្ករយកម៉ោផ្ទុកហើយអញ្ជឹងយើងដាំស្រូវ ដាំអង្ករអីខ្លះយកមកទុកអីទៅ វាទប់ៗរហូតមកដល់សព្វថ្ងៃព្រៃងាប់ចង់អស់ ឡើងណែនដូវមុខផ្ទះនេះឡើងណែនទាំងអស់ ព្រោះពីដើមមានចំការគេចំការឡើងម៉ោថ្នល់នោះ ។

ប៊ុនថន ៖ ចុះអ៊ំចង់សួរមួយទៀតអ៊ំដូចថា សព្វថ្ងៃនេះមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមហើយមានមេដឹកនាំខ្មែរក្រហម៤រូបកំពុងតែឃុំឃាំងហើយរង់ចាំថ្ងៃកាត់ទោស អ៊ំគិតថាយ៉ាំងម៉េចដែរអ៊ំ?

ខុត ៖ អាហ្នឹងស្រេចតែខាងលើវិនិច្ឆ័យដាក់ស្ដេង អ្នកណាធ្វើបាបគេអ្នកហ្នឹងតាមទទួលទោសកំហុសរបស់ខ្លួន បើថាអត់ទេអាហ្នឹងតាមស្មារតីរបស់ខ្លួនឯងអាហ្នឹង ប៉ុនមិនដឹងអ្នកណាធ្វើបាបអ្នកណាទេខ្ញុំមិនសូវដឹងដែរ មុខក៏មិនសូវដែលឃើញទៀត ។

ប៊ុនថន ៖ ចុះអ៊ំមានអីចង់បន្ថែមទៀតទេអ៊ំ?

ខុត ៖ អត់ទេ!ខ្ញុំអត់មានទេ ។

ប៊ុនថន ៖ អញ្ចឹងខ្ញុំអរគុណអ៊ំច្រើនអ៊ំ ។

ខុត ៖ បាទៗ! ។

**ចប់**